ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍

## កិច្ចប្រជុំប្រចាំត្រីមាសទីពីរក្រុមការងារបច្ចេកទេស

## ថ្នាក់ជាតិ បុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍

## ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ នៅភោជនីយដ្ឋាន អ័រគីដេ

### ១-សាវតា

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ពិសេសក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ សហការនិងគាំទ្រថវិកា ដោយអង្គការសេវាសង្គមសុខភាពបុរស(MHSS) បានរៀបចំនូវកិច្ចប្រជុំប្រចាំត្រីមាសទីពីរនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ នៅភោជនីយដ្ឋាន អ័រគីដេ នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ ដោយមានការចូលរួមពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលរួមមានសមាសភាពមកពីក្រុមការងារ បច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ក្រុមគោលដៅដែលជាបុរសស្រឡាញ់បុរស និងស្រីស្រស់មកពីសហគមន៍ផ្ទាល់ លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ស្នងការនគរបាលខេត្ត រួមមានខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងកំពង់ចាម ប្រមាណជាសែសិបនាក់។

### ២-គោលបំណង

១. ពង្រឹងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវា ក្នុងបទអន្តរាគមន៍បង្ការការរីករាលដាលមេរោគអេដស៍និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

២. ពង្រឹងសកម្មភាពការងារក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

តាមរយៈនៃកិច្ចប្រជុំ សមាជិកក្រុមការងារទាំងអស់រំពឹងថា នឹងទទួលបាននូវអនុសាសន៍ល្អៗពីកិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ដើម្បីពង្រឹងសកម្មភាពការងារក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់

បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ និងជំរុញកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវា ក្នុងបទអន្តរាគមន៍បង្ការការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍។

## ៣-កាលបរិច្ឆេទ ទីកន្លែង និងវត្តមាន

កាលបរិច្ឆេទ : ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦

ទីកន្លែង : នៅភោជនីយដ្ឋាន អ័រគីដេ

វត្តមាន : អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សមាជិកក្រុមការងារបច្ចេកទេសថ្នាក់ជាតិ ក្រុមគោលដៅ និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ស្នងការនគរបាលខេត្តពោធិ៍សាត់ បាត់ដំបង សៀមរាប និងបន្ទាយមានជ័យ ។

## ៤-វិធីសាស្ត្រ

កិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបានប្រើប្រាស់វិធីសាស្ត្រសំខាន់ៗមួយចំនួនដូចជា បទបង្ហាញជាស្លាយ ការពិភាក្សាក្រុមធំ បទបង្ហាញវេទិកាសំណួរ និងចំឡើយរវាងអ្នកចូលរួម និងវាគ្មិន ព្រមទាំងការផ្តល់ជាអនុសាសន៍ក្នុងការរៀបចំផែនការសកម្មភាពសំរាប់អនុវត្តការងារបន្ត។



ឯកឧត្តមប្រធាននៃកិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ជាតិ

**៥-លទ្ធផល**

កាលពីថ្ងៃសុក្រ ទី២៤ ខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោង៨:៣០នាទីព្រឹក នៅភោជនីយដ្ឋាន អ៊័រគីដេ ក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដោយសហការជាមួយអង្គការសេវាសង្គមសុខភាពបុរស(MHSS) បានរៀបចំនូវកិច្ចប្រជុំប្រចាំត្រីមាសទីពីររបស់ខ្លួនក្រោមកិច្ចដឹកនាំប្រជុំដោយ ឯកឧត្តមវេជ្ជ. **តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមការឧបត្ថម្ភថវិកាពីអង្គការសេវាសង្គមសុខភាពបុរសដោយសម្រេចលទ្ធផលដូចខាងក្រោម៖

១. មតិស្វាគមន៍ និងបើកកិច្ចប្រជុំ

មតិស្វាគមន៍ និងបើកកិច្ចប្រជុំ ដោយឯកឧត្តមប្រធានអង្គប្រជុំ បានថ្លែងអំណរគុណដល់សមាជិកក្រុមការងារបច្ចេកទេសថ្នាក់ជាតិជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ តំណាងក្រសួងពាក់ព័ន្ធ អ្នកអនុវត្តច្បាប់ ដែលបានចូលរួមប្រជុំនាពេលនេះ និងបានអរគុណដល់អង្គការសេវាសង្គមសុខភាពបុរស ដែលតែងតែឧបត្ថម្ភថវិកាដល់ការរៀបចំកិច្ចប្រជុំប្រចាំត្រីមាសនេះឡើង។ ឯកឧត្តមបានមានប្រសាសន៍ថាកិច្ចប្រជុំនេះធ្វើឡើងក្នុងគោលបំណងពង្រឹងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវា ក្នុងបទអន្តរាគមន៍បង្ការ ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ និងពង្រឹងសកម្មភាពការងារក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។ ជាមួយគ្នានេះ ឯកឧត្តមប្រធាន បានមានប្រសាសន៍បន្តទៀតថា ការធ្វើបទអន្តរាគមន៍បង្ការលើក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ យើងត្រូវរិះរកវីធីសាស្រ្តថ្មីៗ និងជំរុញសហការជាមួយអាជ្ញាធរមូលដ្ឋាន បង្កឲ្យមានបរិយាកាសគាំទ្រក្នុងសហគមន៍ ពិសេសផ្តោតលើខេត្តសំខាន់ៗ ក្រុមលាក់មុខដើម្បីជំរុញ និងលើកទឹកចិត្តឲ្យទៅទទួលសេវាសុខភាព។

២.ជាកិច្ចបន្តការធ្វើបទបង្ហាញ:

២.១ ការបង្ហាញពីរបាយការណ៍វឌ្ឍន៍ភាពបទអន្តរាគមន៍បង្ការមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ឆ្នាំ២០១៥៖



នៅក្នុងបទបង្ហាញនោះ វាគ្មិនបានបង្ហាញពីលទ្ធផលដែលបានសម្រេច ពីឧបសគ្គនានា និងពីកង្វះថវិការបស់ក្រុមការងារក្នុងការអនុវត្តន៍ការងារ។ តាមរយៈរបាយការណ៍នេះ ក៏បានបង្ហាញពីកិច្ចសម្របសម្រួល និងសហការរវាងអាជ្ញាធរមូលដ្ឋាន និងអង្គការជាដៃគូ។ ជាមួយគ្នានោះក៏បានលើកសំណូមពរ ឬផ្តល់ជាអនុសាសន៍ក្នុងការរៀបចំផែនការសកម្មភាពសំរាប់អនុវត្តបន្ត។

២.២ ការបង្ហាញពីបច្ចុប្បន្នភាពនៃការអនុវត្តន៍សកម្មភាពការងាររបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់នៅកម្ពុជា៖

-លទ្ធផលសម្រេចបានរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រចាំត្រីមាសទី២ ឆ្នាំ២០១៦៖

១.បានរៀបចំរបាយការណ៍វឌ្ឍន៍ភាពប្រចាំឆ្នាំ២០១៥ របស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

២.បានកែសម្រួលសេចក្តីសម្រេចស្តីពីក្រុមការងារបច្ចកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣. បានប្រជុំក្រុមការងារលេខាធិការដ្ឋាន និងក្រុមការងារបច្ចេកទេសថ្នាក់ជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រចាំខែ និងប្រចាំត្រីមាសជាទៀងទាត់។

៤. បានរៀបចំផែនការសម្មភាពលំអិតប្រចាំឆ្នាំ២១០៦។

- សកម្មភាពសំខាន់ៗរបស់អង្គការដៃគូ៖

១. ផ្នែកបង្ការ: មានអង្គការ AHF, KHEMARA, MHSS, MHC, SIT

- អប់រំ
- ចែកស្រោមអនាម័យ
- បញ្ជូនទៅរកសេវាពិនិត្យសុខភាព

- តេស្តឈាម
- ការគ្រប់គ្រងករណី

២. ផ្នែកព្យាបាល ថែទាំ និងគាំទ្រ: មានអង្គការ MEC, RHAC, CHOUK SOR, CPN+, AHF។

- VCCT
- STI/RTI
- PHC (Primary Health Care)
- Pre-ART and ART
- Referral

- លទ្ធផលសំរេចបានប្រចាំត្រីមាសរបស់អង្គការដៃគូ




ការចែកស្រោមអនាម័យ
Total
285042
AHF
16287
SIT
10293
KHEMARA
24421
MHC
14495
MHSS
219546


ការបញ្ជូនទៅទទួលសេវាជំងឺកាមរោគ
MSM
IG
Total
2193
165
2358
280
146
426
429
78
507
141
71
212
3043
460
3503
MHSS
MHC
KHEMARA
SIT
Total




- ការសម្របសម្រួល និងបរិយាកាសគាំទ្រ៖

១.ប្រារព្ធពីធីសប្តាហ៍មោទនភាព(Pride Week) និងទិវាប្រឆាំងការស្អប់ខ្ពើមអ្នកស្រឡាញ់ភេទដូចគ្នា នៅភ្នំពេញ សៀមរាប តាកែវ និងខេត្តមួយចំនួនទៀត។

២.ចូលរួមរៀបចំកិច្ចប្រជុំសម្របសម្រួលជាមួយគណៈកម្មការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តបាត់ដំបង ដើម្បីពង្រឹងកិច្ចសហការរវាងគម្រោង និងដៃគូពាក់ព័ន្ធ។

៣.រៀបចំកិច្ចប្រជុំថ្នាក់ក្រោមជាតិសំរាប់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

៤.រៀបចំទិវាស្រោមអនាម័យអន្តរជាតិ។




ទិវាស្រោមអនាម័យអន្តរជាតិ

២.៣ បទបង្ហាញពីទិសដៅ៩០ ៩០ ៩០ ក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ជាសកល និងកម្ពុជា៖

-ការងារជាយុទ្ធសាស្ត្រ និងការប្តេជ្ញាចិត្តឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍របស់អង្គការសហប្រជាជាតិនៅកម្ពុជា ២០១៦-២០២១ ដោយអនុវត្តនូវគោលការណ៍សូន្យបី ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបញ្ចប់ការចំលងមេរោគអេដស៍ថ្មី នាឆ្នាំ២០៣០។

-គោលដៅសំខាន់ៗចំនួនប្រាំមួយ ដែលជាប់ទាក់ទងនឹងក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងចំណោមគោលដៅទាំងដប់របស់អង្គការសហប្រជាជាតិ រួមមាន៖

១. គោលដៅទីមួយ ៩០ ៩០ ៩០៖ ៩០% នៃមនុស្សទាំងអស់ដែលមានផ្ទុកមេរោគអេដស៍ បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ពួកគេ ៩០% នៃអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ដែលបានពេគវិនិច្ឆ័យបានបន្តទទួលការព្យាបាលឱសថប្រឆាំងនឹងមេរោគអេដស៍ជាប់ជាប្រចាំ ៩០% នៃមនុស្សទាំងអស់ ដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ មិនអាចរកឃើញផ្ទុកមេរោគអេដស៍នៅក្នុងខ្លួន។

៦. ៩០ភាគរយនៃក្រុមប្រឈមមុខខ្ពស់៖ អ្នកធ្វើការនៅតាមគ្រឹះស្ថានកំសាន្ត ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ អ្នកប្រើប្រាស់គ្រឿងញៀន ប្រជាជនចល័ត ឫចំណាកស្រុក និងអ្នកជាប់មន្ទីរឃុំឃាំង ត្រូវបានទទួលសេវាបង្ការ និងព្យាបាលមេរោគអេដស៍ និងជំងឺអេដស៍។

៧. ៩០ភាគរយនៃអ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ និងផលប៉ះពាល់មិនត្រូវបានការរំលោភបំពានដោយអំពើហឹង្សា។

៨. ៩០ភាគរយមិនត្រូវមានការរើសអើង និងមាក់ងាយទោះបីជានៅកន្លែងធ្វើការសាលារៀន និងនៅសេវាសុខាភិបាល។

១០. ៧៥ភាគរយនៃអ្នករស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ និងផលប៉ះពាល់ត្រូវបានទទួលការគាំពារសេវាសង្គម។

-សមាជិកអង្គការសហប្រជាជាតិដែលធ្វើការនៅប្រទេសកម្ពុជាក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ រួមមាន៖

- UNAIDS
- UNODC (United Nations Office on Drugs and Crime)
- World Health Organization
- Unicef ( Unite for Children)
- WFP(World food Programme)
- IOM-OIM
- ILO
- UNFPA

- UNESCO
- UNDP
- UN Volunteers
- UNWOMEN

- គោលដៅបច្ចុប្បន្នរបស់អង្គការសហប្រជាជាតិ ផ្តោតសំខាន់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមចំណែកឆ្លើយតបផែនការយុទ្ធសាស្ត្រជាតិដែលមានលក្ខណៈជាពហុវិស័យ ក្នុងការជំរុញកម្មវិធីបង្ការ និងការព្យាបាល និងបង្កបរិយាកាសគាំទ្រដល់ក្រុមប្រឈមមុខ។

២.៤ ផែនការសកម្មភាពបន្ទាប់

យុទ្ធសាស្ត្រទី១ :បង្ការការឆ្លងមេរោគអេដស៍ថ្មីក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់

គោលដៅទី១:បង្កើនការប្រើប្រាស់សេវាធ្វើតេស្តឈាមដោយគ្មានការរើសអើង និងម៉ាក់ងាយដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់

| | |
|---|---|
| ១ | សម្របសម្រួលកិច្ចប្រជុំបង្កើនការប្រើប្រាស់សេវាមេរោគអេដស៍ជាមួយNCHADSអង្គការដៃគូ និងស្ថាប័នពាក់ព័ន្ធ |
| ២ | ចុះអភិបាលកិច្ចទៅលើគុណភាពនៃការផ្តល់សេវាសុខភាព |
| ៣ | រៀបចំកិច្ចប្រជុំផ្តល់យោបល់ និងវាយតម្លៃបន្ទាប់ពីចុះអភិបាលកិច្ចមកពិភាក្សាជាមួយក្រុមការងារលេខាធិការដ្ឋាន |
| ៤ | រៀបចំកិច្ចប្រជុំសម្របសម្រួលថ្នាក់ក្រោមជាតិ (ថ្នាក់មូលដ្ឋាន) ដល់អ្នកផ្តល់សេវា គ្រួសារ និងអាជ្ញាធរដែនដី (ការរើសអើង និងការទទួលសេវាសុខភាព) |

យុទ្ធសាស្ត្រទី២: បង្កើត និងធានានិរន្តភាពបរិយាកាសគាំទ្រកម្មវិធីបង្ការមេរោគអេដស៍ និងជំងឺអេដស៍ និងកាមរោគសម្រាប់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់

គោលដៅទី២: បង្កើនការសហការ និងសម្របសម្រួលគ្រប់ដៃគូទាំងអស់

| | |
|---|---|
| ១ | រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការចូលរួមដល់ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធក្នុងកម្មវិធីបង្ការមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ តាមរយៈក្រសួងព័ត៌មាន |
| ២ | សម្របសម្រួលជាមួយ NCHADS និងដៃគូពាក់ព័ន្ធក្នុងការពង្រីកសេវាបង្ការ ថែទាំ និងគាំទ្រដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ |
| ៣ | រៀបចំកិច្ចប្រជុំសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីការកាត់បន្ថយការរើសអើង និងមាក់ងាយ ដើម្បីពង្រឹងការអនុវត្តន៍បទអន្តរាគមន៍បង្ការមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ |

| | |
|---|---|
| ៤ | បង្កើតវេទិកាជាមួយសារព័ត៌មាន ដើម្បីកាត់បន្ថយការរើសអើងក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ |

យុទ្ធសាស្ត្រទី៣: ពង្រឹងសមត្ថភាពដៃគូពាក់ព័ន្ធ

គោលដៅទី៣: ពង្រឹងការចូលរួមរបស់អង្គការសហគមន៍ ដែលធ្វើការងារជាមួយក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍

| | |
|---|---|
| ១ | រៀបចំប្រមូលរបាយការណ៍ជាមួយអង្គការដែលធ្វើការងារជាមួយក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ |
| ២ | បង្កើនសមត្ថភាពដល់ក្រុមការងារលេខាធិការដ្ឋាន |
| ៣ | រៀបចំផ្លាស់ប្តូរបទពិសោធន៍តាមរយៈកម្មសិក្សាឬការចូលរួមកិច្ចប្រជុំនានាជាមួយអ្នកពាក់ព័ន្ធ |

យុទ្ធសាស្ត្រទី៤: លើកកំពស់លើការប្រមូល និងប្រើប្រាស់ព័ត៌មានជាយុទ្ធសាស្ត្រ

គោលដៅទី៤:ត្រួតពិនិត្យ និងតាមដានកម្មវិធីក្រុមបុរសស្រឡាញ់បុរសនិងស្រីស្រស់ ការកែលំអរ និងវាយតម្លៃសមត្ថភាព ប្រសិទ្ធភាព និងផលប៉ះពាល់ នៃបទអន្តរាគមន៍

| | |
|---|---|
| ១ | ចុះត្រួតពិនិត្យ និងប្រមូលទិន្នន័យ ព័ត៌មាន ពីអង្គការក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ អ្នកផ្តល់សេវា និងសហគមន៍ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ |
| ២ | បង្កើតទម្រង់ប្រមូលទិន្នន័យសម្រាប់ត្រីមាសនីមួយៗ |
| ៣ | ជំរុញឱ្យស្ថាប័នធ្វើការងារជាមួយបុរសស្រឡាញ់បុរស និងស្រីស្រស់ពង្រឹងការអនុវត្តន៍ការងារថ្នាក់សហគមន៍(សមត្ថភាព ប្រាក់ឧបត្ថម្ភ គ្រឿងលើកទឹកចិត្ត) |
| ៤ | រៀបចំកិច្ចប្រជុំ ឬវេទិកាផ្លាស់ប្តូរយោបល់ជាមួយអង្គការពាក់ព័ន្ធ គ្លីនិក និងមណ្ឌលសុខភាព ដើម្បីផ្លាស់ប្តូរយោបល់ និងព័ត៌មាន |
| ៥ | រៀបចំកិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ |
| ៦ | រៀបចំកិច្ចប្រជុំប្រចាំខែនៃក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ |
| ៧ | រៀបចំកិច្ចប្រជុំបូកសរុបការងារប្រចាំឆ្នាំរបស់ក្រុមការងារលេខាធិការដ្ឋានប្រចាំឆ្នាំ២០១៦ |

៦.បញ្ហាប្រឈម:

- ក្រុមបុរសស្រឡាញ់បុរសមិនបានធ្វើតេស្តឈាម ដោយសារគាត់គិតថាការប្រព្រឹត្តរបស់គាត់មិនមានការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ទេ។
- ក្រុមគោលដៅមួយចំនួនមានការចល័ត នៅលាក់មុខ និងមិនហ៊ានទទួលយកសេវាសុខភាពទូលំទូលាយនៅឡើយទេ។
- ការចូលរួមប្រជុំរបស់បណ្តាញចតុមុខមិនបានទៀងទាត់។
- មិនមានថវិកាគ្រប់គ្រាន់ក្នុងការឧបត្ថម្ភដល់អ្នកពាក់ព័ន្ធ ដើម្បីចូលរួមកិច្ចប្រជុំប្រចាំខែ ប្រចាំត្រីមាស និងសកម្មភាពសំខាន់ៗមួយចំនួន។
- ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ខ្លះពួកគាត់ជាប់រវល់ការងារ កំឡុងពេលអ្នកអប់រំតាមមូលដ្ឋានចុះធ្វើការអប់រំ និងធ្វើតេស្តឈាមនៅតាមសហគមន៍។
- មិនបានធ្វើតេស្តឈាមដោយគាត់ខ្លាចថាគាត់បានឆ្លងមេរោគអេដស៍។
- ខ្លាចការមាក់ងាយ និងការរើសអើងពីគ្រួសារ និងសង្គម។
- ខ្វះខាត និងការផ្គត់ផ្គង់ប្រតិករសំរាប់ធ្វើតេស្តមិនទាន់ពេល។
- ខ្វះខាតឧបករណ៏សំរាប់អនុវត្តការធ្វើតេស្តឈាម។
- ការស្វែងរកករណីចម្លងថ្មីនៅមានកំរិតទាប ជាពិសេសក្រុមលាក់មុខមិនអាចឆ្លើយតបតាមគោលការណ៍៩០ ៩០ ៩០ នាឆ្នាំ២០២៥។
- ខ្វះខាតប្រតិករសំរាប់ធ្វើតេស្តឈាម ជាពិសេសតេស្តស្វាយ។
- ខ្វះឧបករណ៏សំរាប់អនុវត្តបំរើអោយការធ្វើតេស្តឈាម។
- ការអប់រំផ្សព្វផ្សាយដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ តាមបណ្តាខេត្តនានាមិនទាន់បានទូលំទូលាយ ទាំងការអប់រំឥរិយាបទ សីលធម៌សង្គម អត្តចរិក និងសេវាសុខភាព។
- ខ្វះការសិក្សាពីបរិបទរបស់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។
- សមាជិក សមាជីការក្រុមលេខាធិការដ្ឋានចូលរួមកិច្ចប្រជុំប្រចាំខែមិនសូវបានទៀងទាត់។
- ការផ្តល់របាយការណ៍ ឬទិន្នន័យលើការងារបុរសស្រឡាញ់បុរស និងស្រីស្រស់នៅពេលស្នើសុំមានការយឺតយ៉ាវ។

• ម្ចាស់សេវាមួយចំនួនតូចមិនទាន់មានកិច្ចសហការបានរលូននៅឡើយលើការចុះពិនិត្យ និងធ្វើតេស្តឈាមនៅតាមទីតាំងផ្ទាល់។

• មិនទាន់មានការគាំទ្រឬការផ្តល់អោយលើវិជ្ជាជីវៈសង្គមសម្រាប់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ដើម្បីលើកកម្ពស់ជីវភាពរបស់ពួកគេ។

• មិនមានយន្តការច្បាស់លាស់ក្នុងការប្រមូលព័ត៌មានរបស់ក្រុមលេខាធិការដ្ឋាន។

• ពិបាកប្រមូលផ្តុំក្រុមគោលដៅចូលរួមសកម្មភាពអប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមនៅតាមកន្លែងប្រមូលផ្តុំ។

• ការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយជោះចុងម្រាមដៃមិនបានគ្រប់ផែនការ។

• អ្នកអប់រំមូលដ្ឋានមិនទាន់បានទទួលការបណ្តុះបណ្តាលពីការផ្តល់ប្រឹក្សា និងការធ្វើតេស្ត។

• ថវិកាបញ្ជូនទៅរកសេវារបស់ក្រុមគោលដៅនៃអង្គការដៃគូមិនគ្រប់គ្រាន់។

• អង្គការដៃគូមិនមានបុគ្គលិកទទួលបន្ទុកគ្រប់គ្រងករណីវិជ្ជមាន។

• ក្រុមគោលដៅវិជ្ជមានមួយចំនួនមិនព្រមមកទទួលសេវាទាន់ពេល។

• អង្គការដៃគូមួយចំនួនមិនទាន់មានបុគ្គលិកប្រចាំការនៅតាមមន្ទីរពេទ្យ។

• ក្រុមគោលដៅមួយចំនួនបដិសេធន៍មិនទទួលយកប្រតិកម្មតេស្ត។

• ក្រុមគោលដៅមួយចំនួនព្រមទៅធ្វើតេស្តបញ្ជាក់តែមិនទទួលការព្យាបាល។

**៧. សំណូមពរ និងអនុសាសន៍:**

• ត្រូវពិនិត្យឡើងវិញនៅរបាយការណ៍ប្រចាំឆ្នាំ២០១៥ ការដាក់ទិន្នន័យនីមួយៗត្រូវរកឯកសារយោងមកសំអាង។

• ត្រូវជំរុញការអប់រំ និងផ្សព្វផ្សាយដល់សហគមន៍ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

• ស្នើសុំថវិកាពីអង្គការ KHANA & UNAIDS សំរាប់បោះពុម្ពរបាយការណ៍ប្រចាំឆ្នាំ២០១៥ បន្ទាប់ពីធ្វើការកែសម្រួលរួច និងឈានទៅដល់ការបកប្រែជាភាសាអង់គ្លេស។

• ស្នើសមាជិកលេខាធិការដ្ឋាន រាល់ការបង្ហាញលទ្ធផល ត្រូវធ្វើការប្រៀបធៀបពីត្រីមាសមួយទៅត្រីមាសមួយទៀត ឬពីពេលមួយទៅពេលមួយទៀត។

• ស្នើសមាជិកលេខាធិការដ្ឋាន រៀបចំកិច្ចប្រជុំជាបន្ទាន់ជាមួយ NCHADS និង KHANA ដើម្បីដោះស្រាយបញ្ហាបច្ចេកទេស។

• ការចុះអភិបាលកិច្ច ត្រូវមានផែនការ និងកំណត់គោលដៅច្បាស់លាស់ និងមានយុទ្ធវិធីក្នុងការចុះតាមដាន និងប្រមូលមកវិញនូវចំណុចខ្វះខាតនៅសហគមន៍ និងរកដំណោះស្រាយ។

• ត្រូវធ្វើការសិក្សាពីបរិបទ អត្តចរិករបស់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ដើម្បីកាត់បន្ថយការរើសអើង និងមាក់ងាយក្នុងសង្គម។

• ត្រូវរកយុទ្ធវិធីថ្មីៗក្នុងការជំរុញលើកទឹកចិត្តដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រើប្រាស់ឲ្យបានជាប់លាប់ស្រោមអនាម័យ។

• ត្រូវជួយបណ្តាញថ្នាក់ជាតិក្នុងការពង្រឹងស្ថាប័នរបស់ខ្លួន និងដើរតួនាទីជាអ្នកសម្របសម្រួលតាំងពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ(សហគមន៍)។

• សំណូមពរដល់សមាជិកសូមបរិច្ចាកពេលវេលា ដើម្បីចូលរួមកិច្ចប្រជុំទាំងក្រុមការងារលេខាធិការដ្ឋាន ក៏ដូចក្រុមការងារបច្ចេកទេសឲ្យទៀងទាត់ និងគ្រប់ៗគ្នា។

• សំណូមពរដល់អ្នកចូលរួមធ្វើបទបង្ហាញជាខេមរៈភាសា និងត្រួតពិនិត្យលើអក្ខរាវិរុទ្ធឲ្យបានត្រឹមត្រូវ។

• សូមជួយផ្តល់របាយការណ៍ ឬទិន្នន័យលើការងារបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅពេលស្នើសុំពីលេខាធិការដ្ឋាន។

• ពង្រឹង និងបង្កើនសមត្ថភាពដល់បុគ្គលិក និងអ្នកអប់រំផ្ទាល់។

• ព្យាយាមស្វែងរកក្រុមគោលដៅថ្មី និងតាមដានគ្រប់ករណីដែលបានរកឃើញ។

• ព្យាយាមផ្តល់ការប្រឹក្សាបន្ថែមអំពីបញ្ហាសុខភាព ឥរិយាបទ និងសីលធម៌សង្គមដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។




## ៨. ផែនការបន្ទាប់:

• សម្របសម្រួលរៀបចំប្រជុំក្រុមការងារលេខាធិការដ្ឋាន និងប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

• បន្តរិះរកយុទ្ធវិធីចូលទៅដល់ក្រុមប្រឈមមុខខ្ពស់ ពិសេសក្រុមដែលលាក់មុខ ដែលមិនបានអប់រំ ដើម្បីឲ្យពួកគេទទួលបានព័ត៌មានអំពីសុខភាព និងតាមដានអ្នកដែលមានផ្ទុកមេរោគអេដស៍ដើម្បីទទួលបានសេវា PreART/ART

• សម្របសម្រួលរៀបចំកិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារថ្នាក់ក្រោមជាតិនៃបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

• បន្តចុះអប់រំ និងជំរុញការប្រើស្រោមអនាម័យ និងទឹករំអិលដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅពេលពួកគេចុះអប់រំជាក្រុម ឬអប់រំនៅតាមផ្ទះ។

• បន្តជំរុញ និងពង្រឹងបទអន្តរាគមន៍បង្ការដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ទៅរកសេវា។

• ប្រមូលរបាយការណ៍ពីអង្គការដៃគូធ្វើការជាមួយក្រុមបុរសស្រឡាញ់បុរសនិងស្រីស្រស់។

• បន្តកិច្ចសហការល្អជាមួយ អាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវា បុគ្គលិកអង្គការ និងអ្នកទទួលផលធ្វើអោយប្រព័ន្ធនៃការបញ្ជូនទទួលបានជោគជ័យ។

• បណ្តុះបណ្តាលដល់អ្នកអប់រំតាមសហគមន៍ ឲ្យមានចំណេះដឹងក្នុងការផ្តល់ប្រឹក្សាជាកត្តាធ្វើឲ្យក្រុមគោលដៅមានទំនុកចិត្តក្នុងការទៅទទួលសេវាពិនិត្យសុខភាព។

• បន្តកិច្ចសហការជាមួយអាជ្ញាធរដែនដី និងកងកំលាំងមានសមត្ថកិច្ច និងអង្គការសហគមន៍ និងក្រុមគោលដៅជួយការងារសង្គម ក្នុងគោលបំណងកាត់បន្ថយការមាក់ងាយ និងរើសអើងក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។



ជាទីបញ្ចប់ ឯកឧត្តមប្រធាន បានអរគុណ និងបានកោតសរសើរចំពោះសមាជិកដែលបានចូលរួមប្រជុំនាពេលនេះ និងសូមឲ្យខិតខំបន្តសហការគ្នាល្អ និងជំរុញការងារឆ្លើយតបការទប់ស្កាត់រីករាលដាលមេរោគអេដស៍និងជំងឺអេដស៍ដើម្បីសំរេចបាននូវគោលការណ៍៩០៩០៩០នាឆ្នាំ២០២៥។

ភ្នំពេញថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦

អ្នកធ្វើរបាយការណ៍

បានឃើញ និងពិនិត្យត្រឹមត្រូវ

បានឃើញ និងឯកភាព

ប្រធាននាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ

ឯកឧត្តមអគ្គលេខាធិការ

7-7-16